ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍សង្ខេបកិច្ចប្រជុំ
ពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១
ឆ្នាំ២០២៣

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣

រៀបចំដោយ: អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ: ថវិកាជាតិ

១.សេចក្តីផ្តើម

យោងតាមអាណត្តិ និងបេសកកម្មដែលកំណត់ដោយព្រះរាជក្រមលេខ នស/រកម/ ០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) និងអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមគម្រោងផែនការជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២៣ ក្រុមប្រឹក្សាគោលនយោបាយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទីផ្តល់ជាទិសដៅ និងអនុសាសន៍ក្នុងការកំណត់យុទ្ធសាស្ត្រគោលនយោបាយ ជាតិទូលំទូលាយ និងជាពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រួមជាមួយនឹងការតាមដាននូវការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផល ដែលទទួលបានពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ឆ្នាំ២០២៣ផងនោះ ត្រូវរៀបចំនូវកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន២ដង ក្នុងមួយឆ្នាំ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការគាំទ្រជានយោបាយ ក្នុងការដឹកនាំគ្រប់គ្រង សម្របសម្រួល និងជួយចូលរួមដោះស្រាយរាល់ឧបសគ្គ ការលំបាក និងចំណុចខ្វះខាតនានា ពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រ គោលនយោបាយ សេចក្តីប្រកាស និងសេចក្តីសម្រេចនានា ដែលបានអនុម័តដោយក្រុមប្រឹក្សាបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ហេតុនេះហើយទើបនៅព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អៀង ងួលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** នៅសាលប្រជុំ ទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក-លោកស្រីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងក្រសួង-ស្ថាប័ន ទាំង៣៣ រាជធានី-ខេត្តទាំង២៥ តំណាងអង្គការមិនមែនរដ្ឋាភិបាល ជាតិ អន្តរជាតិ ចំនួន១៨២រូប ដោយមានការឧបត្ថម្ភគាំទ្រពីថវិកាជាតិ។

២.គោលបំណង នៃកិច្ចប្រជុំពេញអង្គ

- ជម្រាបជូនសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីបច្ចុប្បន្នភាពនៃស្ថានភាព រីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

- ជម្រាបជូនសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។
- ពិនិត្យមើលនូវសមិទ្ធផល នៃការអនុវត្តសកម្មភាពការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុង៦ខែដើមឆ្នាំ២០២៣។
- ពិនិត្យពីឧបសគ្គ ការលំបាក និងចំណុចខ្វះខាត ក្នុងការអនុវត្តសកម្មភាពកន្លងមក
- ស្នើសុំការអនុម័តនូវសេចក្តីសម្រេចចិត្ត របស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ប្រចាំឆ្នាំ២០២៣។

៣. កម្មវិធីនៃកិច្ចប្រជុំពេញអង្គ

កិច្ចប្រជុំពេញអង្គបានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម៖

- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសហេតុ គោលបំណង និងរបៀបវារៈនៃកិច្ចប្រជុំ
- សុន្ទរកថាបើកកិច្ចប្រជុំដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បទបង្ហាញ ស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២២ បង្ហាញដូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនជារ៉ត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

- បទបង្ហាញ ស្តីពីការរៀបចំសេចក្តីព្រៀងគោលនយោបាយជាតិបញ្ចប់អេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបនឹងជំងឺអេដស៍ បង្ហាញដូនដោយ **ឯកឧត្តមវេជ្ជ. ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សំណួរ ចម្លើយ និងពិភាក្សារួម
- អនុម័តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣។
- សុន្ទរកថា និងអនុសាសន៍បិទអង្គប្រជុំដោយ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.ដំណើរការប្រព្រឹត្តទៅនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងសុន្ទរកថាបើក។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានស្វាគមន៍ ជាមួយនឹងសេចក្តីសោមនស្សក្រៃលែងដោយបានចូលរួមជាអធិបតីក្នុងការដឹកនាំ **"កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣"** ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាម ឯកឧត្តមផ្ទាល់ ឯកឧត្តមសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរ

ជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គលើកទី១ សម្រាប់ឆ្នាំ២០២៣ នាពេលនេះ។

ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏សូមគោរពថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះក្រសួង ស្ថាប័នពាក់ពន្ធ័ទាំងអស់ នៅក្នុងកិច្ចខិតខំប្រឹងប្រែង និងការសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការជំរុញ និងចូលរួមអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ដោយទទួលលទ្ធផលជាផ្លែផ្កាក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាម **ឯកឧត្តមទេសរដ្ឋមន្ត្រី** ផ្ទាល់ ឯកឧត្តមសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គលើកទី១សម្រាប់ឆ្នាំ២០២៣ នាពេលនេះ។

ក្នុងយន្តការឆ្ពោះទៅរកការពង្រឹងប្រព័ន្ធជាតិ និងភាពជាម្ចាស់ ក្នុងការឆ្លើយតបជាពហុវិស័យចំពោះការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាពនៅកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមវាយតម្លៃខ្ពស់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការចេញប្រកាសលេខ ៥៥៨ សហវ.អហក ស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំសិក្ខាសាលា និងកិច្ចប្រជុំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសលេខ ៥៥៩ សហវ.ប្រក ស្តីពីវិធាន និងនិតិវិធីចំណាយបេសកម្មនៅក្នុង និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ដែលបានជួយគាំទ្រគោលនយោបាយជាតិសម្រាប់ប្រើប្រាស់ថវិការដ្ឋនៅថ្នាក់ក្រោមជាតិ ឆ្លើយតបវិធានការ ៦ចំណុចរបស់សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៩ ។

សមិទ្ធិផលរបស់ប្រទេសកម្ពុជាត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបាននូវអត្រាទទួលសេវាព្យាបាលខ្ពស់បំផុត និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ គិតត្រឹមខែធ្នូ ឆ្នាំ២០២២ អ្នកផ្ទុកមេរោគអេដស៍ ៦៥.៦៤៦នាក់ បានកំពុងទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ដោយឥតគិតប្រាក់ពី មូលដ្ឋានសុខាភិបាលរបស់រដ្ឋត្រូវជា៩៩% នៃអ្នកផ្ទុកមេរោគអេដស៍ដែលដឹងពីស្ថានភាព ដែលកំពុងទទួលបានការព្យាបាល ហើយ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ដែលទទួលការព្យាបាល ត្រូវបានពិនិត្យឃើញថា រកឃើញបន្ទុកមេរោគអេដស៍ទាបបំផុត (Viral load suppression)។ ភាពរឹងមាំច្បាស់លាស់នៃការឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជា បានបញ្ជាក់អំពីសមត្ថភាព នៃការបញ្ចូលអ្នកផ្ទុកមេរោគអេដស៍ឱ្យទៅទទួលសេវាព្យាបាលបានធ្វើរោគវិនិច្ឆ័យរួច និងរក្សាទុកឱ្យនៅព្យាបាល ព្រមទាំងលទ្ធភាពបង្កើនប្រសិទ្ធភាពនៃការព្យាបាលជាអតិបរមា ដែលគេលែងឃើញមេរោគនៅក្នុងខ្លួនអ្នកជំងឺ ជាបច្ច័យនាំឱ្យលែងមានការចម្លងមេរោគ (Undetected = Untransmitable)។ ជាមួយគ្នានេះដែរ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បាន និងកំពុងរៀបចំគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨ តាមរយៈលិខិតលេខ ៩២៧ សជណ ចុះថ្ងៃទីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាថ្មីមួយទៀត និងជាកត្តាមិនអាចខ្វះបាន ដើម្បីសម្រេចគោលដៅលុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសការពង្រឹងប្រព័ន្ធជាតិ (Country System) ក្នុងការឆ្លើយតបជាពហុវិស័យចំពោះការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ឈានទៅសម្រេចឱ្យបានក្នុងពេលឆាប់ៗនូវចីរភាពនៃកម្មវិធីអេដស៍នៅកម្ពុជា។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីផ្តល់សាច់ប្រាក់ជូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩ ហើយក្នុងនោះ គ្រួសារផ្ទុកមេរោគអេដស៍ចំនួនប្រមាណជាង២.០០០គ្រួសារ ក៏ទទួលបានការឧបត្ថម្ភសាច់ប្រាក់ប្រចាំខែពីកម្មវិធីផងដែរ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមវាយតម្លៃខ្ពស់ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានជួយគាំទ្រគោលនយោបាយជាតិរបស់យើង ដោយបានដាក់ចេញ នូវនីតិវិធីជាតិ សម្រាប់ប្រើប្រាស់ថវិការដ្ឋនៅថ្នាក់ក្រោមជាតិ និងផ្តល់ថវិកាសម្រាប់ការងារអេដស៍ ដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ទោះជាក្នុងកម្រិតណាក៏ដោយ ដែលនេះជាកត្តាមិនអាចខ្វះបាន ដើម្បីសម្រេចគោលដៅលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥។

ឯកឧត្តមឧទេសរដ្ឋមន្ត្រី បានជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា យោងតាមគម្រោងផែនការសកម្មភាពឆ្នាំ២០២៣ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ធ្វើឡើងដើម្បីពិនិត្យមើលរួមគ្នានូវវឌ្ឍនភាព សមិទ្ធផល និងប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់រយៈពេល៦ខែដើមឆ្នាំ២០២៣ និងធ្វើការប្រមូល និងពិភាក្សាលើ ជាតុចូល និងអនុសាសន៍មួយចំនួន តាមរយៈការចូលរួមរបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញាដែលមានវត្តមានក្នុងពេលនេះ។

តាមរបៀបវារៈកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួនពីរ រួមមាន ៖

ទី១. បទបង្ហាញ ស្តីពីវឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២២ បង្ហាញជូនដោយ **ឯកឧត្តម បណ្ឌិត ឈឹម យិនដារ៉ែត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ទី២. បទបង្ហាញ ស្តីពីការរៀបចំសេចក្តីព្រៀងគោលនយោបាយជាតិ បញ្ចប់អេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបនឹងជំងឺអេដស៍ឆ្នាំ២០២៣-២០២៨ បង្ហាញជូនដោយ**ឯកឧត្តម វេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

បន្ទាប់មក នឹងមានការពិភាក្សារួមគ្នា និងដាក់ចេញនូវសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣ ។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមរដ្ឋមន្ត្រី** បានបញ្ជាក់ជូនសមាជិក សមាជិកានៃកិច្ចប្រជុំពេញអង្គថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រួមជាមួយដៃគូពាក់ព័ន្ធ បាននឹងកំពុងតែធ្វើដំណើររួមគ្នាប្រកបដោយទស្សនវិស័យច្បាស់លាស់ក្នុងក្តីសង្ឃឹមពិតប្រាកដ ឆ្ពោះទៅរកការលុបបំបាត់ជំងឺអេដស៍ក្នុងពេលដ៏ខ្លីខាងមុខ។ យើងមានក្តីសង្ឃឹម ដោយសារតែយើងទទួលបាននូវការប្តេជ្ញាចិត្ត និងការគាំទ្រនយោបាយដ៏រឹងមាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ យើងនឹងកសាងបាននូវចីរភាព នៃការឆ្លើយតបជាពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។ យើងទាំងអស់គ្នាបង្កើតបាននូវស្ថាប័នដឹកនាំគ្រប់គ្រង និងសម្របសម្រួលតែមួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស យើងមានផែនការយុទ្ធសាស្ត្រជាតិតែមួយ មានប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ឯកឧត្តមរដ្ឋមន្ត្រី មានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ ដែលនឹងផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តអនុវត្តការងារឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងពេលខាងមុខ ឱ្យស្របទៅតាមអនុសាសន៍ សេចក្តីសម្រេចចិត្ត ដែលនឹងផ្តល់ជូន និងដាក់ចេញដើម្បីអនុម័តក្នុងកិច្ចប្រជុំពេញអង្គ នាពេលបន្តិចទៀតនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ការងារពីបណ្តាសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំនេះ និងសង្ឃឹមថា សមាជិក សមាជិកានៃកិច្ចប្រជុំ នឹងចូលរួមពិភាក្សាឱ្យបានទទួលជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងបានប្រកាសបើក "កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣"។

១-បទបង្ហាញរបាយការណ៍វឌ្ឍនភាព ស្តីពីការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២២ បង្ហាញជូនដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

ឯកឧត្តមបណ្ឌិត បានជម្រាបជូនពីបច្ចុប្បន្នភាពនៃស្ថានភាពរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាក្នុងឆ្នាំ២០២២ ដែលក្នុងនោះ អ្នកផ្ទុកមេរោគអេដស៍សរុបមានប្រមាណចំនួន៧៦.០០០នាក់ អ្នកកំពុងទទួលការព្យាបាលដោយប្រើឱសថប្រឆាំងមេរោគអេដស៍មានចំនួន៦៥.៦៤៦នាក់ អ្នកឆ្លងថ្មីមេរោគអេដស៍មានចំនួនប្រមាណ១.៤០០នាក់ អ្នកស្លាប់ទាក់ទង

នឹងជំងឺអេដស៍មានចំនួនប្រមាណ១.១០០នាក់។ អត្រាប្រភ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅ (១៥-៤៩ឆ្នាំ) មានប្រមាណ០.៥% ហើយនឹងអត្រាប្រភ៉ាឡង់ក្នុងចំណោមក្រុមអ្នកបម្រើក្នុងសេវាកម្មាន្ត (EW) មានប្រមាណ៤.៩% ក្រុមបុរសរួមភេទជាមួយបុរស (MSM) មានប្រមាណ៤.០% ក្រុមបំផ្លែងភេទ (TG) មានប្រមាណ៩.៦% ក្រុមប្រើប្រាស់គ្រឿងញៀន (PWUD) មានប្រមាណ៥.៧% និងក្រុមចាក់គ្រឿងញៀន (PWID) មានប្រមាណ១៥.២%។

តាមរយៈគម្លាតនៃការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា **ឯកឧត្តម** បានគូសបញ្ជាក់ថា៖

- ចំណេះដឹងពិតប្រាកដអំពីជំងឺអេដស៍ ក្នុងចំណោមយុវវ័យ ជានារីដែលមានត្រឹមតែ ២៣% និងបុរស២៧% (ឆ្នាំ២០១៤ នារី៣៨% និងបុរស៤៦%(ឆ្នាំ២០២១-២០២២)។
- ក្នុងចំណោមអ្នកឆ្លងមេរោគអេដស៍ថ្មី៤២% ឬមួយភាគបីជាយុវវ័យដែលមានអាយុពី១៥-២៤ឆ្នាំ។
- ក្រុមយុវវ័យទាំងនោះមានចំនួនតែ២៧%ប៉ុណ្ណោះ ដែលយល់ដឹងអំពីវិធីសាស្ត្របង្ការការចម្លងមេរោគអេដស៍ជាពិសេសក្រុមបុរសរួមភេទជាមួយបុរសជាយុវវ័យ។
- ៣៣%នៃក្រុមយុវវ័យដែលប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមមិនដែលបានធ្វើតេស្តឈាមរកមេរោគអេដស៍ទេ ទោះបីជាមានការប្រឈមមុខខ្ពស់ក៏ដោយ។
- ក្រុមបុរសរួមភេទជាមួយបុរសមិនបានដឹងថាខ្លួនមានភាពប្រឈមនឹងមេរោគអេដស៍បើធៀបនឹងក្រុមដែលរួមភេទរវាងបុរស និងស្ត្រី។

ឯកឧត្តម បានជម្រាបជូនពីសកម្មភាព និងលទ្ធផលនៃការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២២ ដោយ **ឯកឧត្តមបណ្ឌិត** បានបង្ហាញនូវភាពខ្លាំង និងការលំបាកក្នុងការអនុវត្តភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា៖

- អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** "ខ្ញុំសូមអំពាវនាវដល់ជនរួមជាតិទាំងអស់ឱ្យចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងចរន្តជាតិតែមួយឆ្ពោះទៅការបញ្ចប់អេដស៍ នៅឆ្នាំ២០២៥"។

- ក្រោមមគ្គុទេសភាព **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** កាកបាទក្រហមកម្ពុជា និងក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិ ក្នុងឆ្នាំ២០២២ សម្រេចបាន៖
  - សារលិខិតចំនួន២ ត្រូវបានផលិត និងផ្សព្វផ្សាយ៖ ទី១. ទិវាជាតិសុខភាពមាតាទារក និងកុមារ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រោមប្រធានបទ "រួមគ្នាពង្រឹងសេវាសុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ យុវវ័យ និងអាហារូបត្ថម្ភ ដើម្បីឈានទៅសម្រេចគោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ២០៣០" និងទី២ទិវាឆ្លងជាតិ-អន្តរជាតិ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ ក្រោមប្រធានបទ "រួមគ្នាជាថ្មី : ពីភស្តុតាងជាក់លាក់ ទៅការអនុវត្តពិតប្រាកដ" ដោយក្នុងសារលិខិតទាំងពីរ ក៏មានបញ្ចូលនូវសារអប់រំបង្ការការចម្លងមេរោគអេដស៍ផងដែរ។
  - អប់រំផ្សព្វផ្សាយអំពីសុខភាពមាតា ទារក និងកុមារ ដោយមានបញ្ជ្រាបសារអប់រំផ្សព្វផ្សាយផ្តោតលើការទប់ស្កាត់ការចម្លងមេរោគអេដស៍ និងស្វាយពីម្តាយទៅកូនផងដែរ បន្ថែមពីលើការថែទាំសុខភាពមុន និងក្រោយសម្រាល ការថែទាំ បំប៉នទារក និងកុមារ បានចំនួន ៤.៨៣៨នាក់។ ផ្តល់អំណោយមនុស្សធម៌ដល់បងប្អូនប្រជាពលរដ្ឋ ដែលកំពុងតែរស់នៅជាមួយមេរោគអេដស៍បានចំនួន១.៣៤៨គ្រួសារ និងអប់រំផ្សព្វផ្សាយអំពីការបង្ការមេរោគអេដស៍បានចំនួន ១.៨៦៣នាក់។
- ២០១៧ កម្ពុជាសម្រេចគោលដៅ ៩០-៩០-៩០ បីឆ្នាំមុនកាលកំណត់របស់អង្គការសហប្រជាជាតិ(២០២០) និងកំពុងស្ថិតលើដំណើរផ្លូវត្រូវក្នុងការឆ្ពោះទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។
- អង្គការ UNAIDS ចេញផ្សាយកាលពីឆ្នាំ២០២១ អត្រាគ្របដណ្តប់នៃសេវាព្យាបាលអេដស៍នៅកម្ពុជា មានអត្រាខ្ពស់ជាងគេនៅតំបន់អាស៊ីប៉ាស៊ីហ្វិក គឺខ្ពស់ជាងប្រទេសថៃ ប្រទេសចិន និងប្រទេសវៀតណាម។
- ជាប្រទេសទី១ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលបានរៀបចំវាយតម្លៃរួចរាល់ក្នុងការធ្វើអន្តរកាល (Transition Readiness Assessment) ផែនទីចង្អុលផ្លូវសម្រាប់និរន្តរភាព(Sustainable Roadmap)នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៣-២០២៩។
- មានយន្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ ("Three Ones" principles)។

- បានកំពុងអនុវត្តការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ផ្អែកលើសសរស្តម្ភបី៖ មគ្គុទេសភាព (Leadership) ភាពជាដៃគូ(Partnership) និងការវិនិយោគ (Investment)។
- មានផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣។
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រេចឱ្យបង្កើតគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

បន្ទាប់មក **ឯកឧត្តមបណ្ឌិត** ក៏បានបង្ហាញពី សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ និងលើកទី២ ឆ្នាំ២០២២ ដោយបានប្រៀបធៀបគ្នាដើម្បីផ្ទៀងផ្ទាត់វឌ្ឍនភាព។

ឯកឧត្តមបណ្ឌិត ក៏បានបង្ហាញរបាយការណ៍ ស្តីពីការជ្រើសរើសយករាជធានី ខេត្ត ដើម្បីគ្រោង និងអនុវត្តថវិកាលើផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍រួមមាន៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ដែលទទួលបានថវិកា ៨០លានរៀល និងខេត្ត១០ទៀតទទួលបានថវិកា ៦០លានរៀល។ ហើយក្នុងនោះដែរ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានជួយសម្របសម្រួលដូចមានខាងក្រោម៖

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានផ្តល់ជំនួយបច្ចេកទេសដល់ក្រសួងជាសមាជិក ក្នុងការរៀបចំផែនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ក្រសួងសម្រាប់ឆ្នាំ២០២១ និងឆ្នាំ២០២២ ស្របតាមផែនការយុទ្ធសាស្ត្រជាតិលើកទី៥។ ជាលទ្ធផល មានក្រសួង ស្ថាប័ន បានរៀបចំគម្រោងផែនការសកម្មភាពចំនួន ២៤/៣០ រីឯក្រសួង ស្ថាប័នដែលបានទទួលបានថវិកាជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សរុបចំនួន ១៣។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបន្តសម្របសម្រួលគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅរាជធានី-ខេត្តចំនួន៤។ ជាលទ្ធផលគឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប មានផែនការយុទ្ធសាស្ត្រសម្រាប់រាជធានី-ខេត្តនីមួយៗ។ ជាលទ្ធផល រាជធានីភ្នំពេញ និងខេត្តទាំង៣ ទទួលបានថវិកាជាតិចំនួន៨០លានរៀល សម្រាប់ធ្វើសកម្មភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើការអនុវត្តគម្រោង Fast-Track City នៅចុងឆ្នាំ២០២២ និងផែនការសកម្មភាពថវិកាឆ្នាំ២០២៣។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការវិភាជថវិកាចំនួន៦០លានរៀលក្នុងមួយខេត្ត ដល់ខេត្តចំនួន

១១ (ឆ្នាំ២០២៣) និង៤០លានរៀល ដល់ខេត្តចំនួន១០ សម្រាប់ការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍(ឆ្នាំ២០២៤)។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បាន និងកំពុងជំរុញដល់គណៈកម្មាធិការអេដស៍ខេត្តទាំង១១ ដែលទទួលបានថវិកាចំនួន៦០លានរៀល រៀបចំផែនការសកម្មភាពថវិកាសម្រាប់ការងារអេដស៍ក្នុងខេត្តនីមួយៗ។

ឯកឧត្តមបណ្ឌិត ក៏បានបង្ហាញពីលទ្ធផលរំពឹងទុក៖ ១០០%នៃអ្នកផ្ទុកមេរោគអេដស៍ ត្រូវបានគ្របដណ្តប់ដោយយន្តការគាំពារសង្គមនៅឆ្នាំ២០២៣ និងបង្កើនការទទួលបានសេវាកម្មគាំទ្រផ្នែកសុខភាព ផ្នែកសង្គម និងផ្នែកច្បាប់។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសម្របសម្រួល និងសហការជាមួយ UNAIDS, UNDP, GIZ ធ្វើការជាមួយក្រសួងផែនការ និង NCHADS ក្នុងការកែសម្រួលលក្ខណសម្បត្តិ និយមន័យ និងប្រព័ន្ធ software ក្នុងការផ្តល់ប័ណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ និងការចុះបញ្ជីផ្តល់ប័ណ្ណសមធម៌នៅកន្លែងផ្តល់សេវា ARVs។
- តាមរយៈទិន្នន័យ NCHADS ត្រីមាសទី១ ឆ្នាំ២០២៣៖ អ្នកផ្ទុកមេរោគអេដស៍ដែលទទួលចុះបញ្ជីក្នុងប្រព័ន្ធ និងទទួលបានប័ណ្ណក្រីក្រ (ប័ណ្ណមូលនិធិសមធម៌សុខាភិបាល) មានចំនួនសរុប ១៣.៤១១នាក់ ក្នុងចំណោមអ្នកដែលកំពុងទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART) ចំនួន ៦៥.៦៤៦នាក់ (ស្មើប្រមាណ ២០.៤៣%) ហើយក្នុងនោះ អ្នកផ្ទុកមេរោគអេដស៍ ដែលទទួលប័ណ្ណសមធម៌ជាបុគ្គល (Individual ID Poor) មានចំនួន ៤.៨៣២នាក់។
- តាមរយៈរបាយការណ៍ពីមូលនិធិជាតិជំនួយសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ មានគ្រួសារក្រីក្រ ដែលផ្ទុកមេរោគអដស៍មានចំនួន ២.១៥៣គ្រួសារ ដែលទទួលបានការឧបត្ថម្ភសាច់ប្រាក់ប្រចាំខែ ក្នុងនោះប័ណ្ណសមធម៌កម្រិត១ ចំនួន ៦៩៩គ្រួសារ និងប័ណ្ណសមធម៌កម្រិត២ចំនួន ១.៤៥៤គ្រួសារ។

ឯកឧត្តមបណ្ឌិត ក៏បានបញ្ជាក់ជូនដែរថា បច្ចុប្បន្ននេះរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់កិច្ចគាំពារសង្គម ដល់បុគ្គលបម្រើការងារសេវាកម្មាន្តទេសចរណ៍ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ មនុស្សពេញវ័យដោយធ្វើប័ណ្ណសមធម៌ព័ណ៌លឿង (មូលនិធិសមធម៌សុខាភិបាល/ម.ស.ស) ជូន។

ឯកឧត្តមបណ្ឌិត បានបញ្ជាក់ថា ទោះជាយើងធ្វើការជោគជ័យច្រើនយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមដូចជា៖

- គោលដៅ៩៥ទី១៖ មិនទាន់បានសម្រេចដល់គោលដៅ៩៥% នៅឡើយ (បច្ចុប្បន្ន បាន៨៦%) ហើយអត្រាចម្លងមេរោគអេដស៍ថ្មី ស្ថិតក្នុងចំណោមក្រុមយុវវ័យអាយុ ពី១៥-២៤ឆ្នាំ ជាពិសេសយុវជនរួមភេទដូចគ្នា មានអត្រាឆ្លងមេរោគអេដស៍ ខ្ពស់។ ចំណេះដឹងអំពីការការពារមេរោគអេដស៍ ក្នុងចំណោមយុវវ័យទាំង២ភេទ អាយុពី១៥-២៤ឆ្នាំ មានកម្រិតទាប។
- ករណីឆ្លងមេរោគអេដស៍ថ្មី នៅមានកម្រិតខ្ពស់នៅឡើយ គឺ១.៤០០នាក់/ឆ្នាំ (៨៣% ស្ថិតក្នុងចំណោមប្រជាជនគន្លឹះ និងដៃគូរួមភេទរបស់ពួកគេ)។
- ក្រុមបុរសរួមភេទជាមួយបុរសជាយុវវ័យ៥០% មិនទទួលស្គាល់ថាខ្លួនជាអ្នកប្រឈម មុខនឹងការឆ្លងមេរោគអេដស៍ឡើយ។
- បទអន្តរាគមន៍បង្ការលើក្រុមបុរសរួមភេទជាមួយបុរស និងស្ត្រីបម្រើសេវាកម្សាន្ត សប្បាយបានតែ៥០% (IBBS, 2022)។
- អត្រាប្រើប្រាស់ជាប់លាប់សេវាបង្ការមុនការចម្លងមេរោគអេដស៍ (PrEP) នៅមាន កម្រិតត្រឹម៥០% នៅឡើយ។
- គោលដៅអត្រាចម្លងមេរោគអេដស៍ ពីម្តាយទៅកូនគឺត្រូវតិចជាង៥% ប៉ុន្តែ បច្ចុប្បន្នស្ថិតនៅកម្រិត ៩.៩% នៅឡើយ។
- ការអនុវត្ត ស.ជ.ណ. ២១៣ នៅមិនទាន់ពេញលេញដូចជា ៖ ការធ្វើសមាហរណ កម្មការងារអេដស៍ ចូលក្នុងផែនការវិនិយោគឃុំ សង្កាត់។
- ការត្រៀមខ្លួនក្នុងការទទួលយកភាពជាម្ចាស់ក្នុងការដឹកនាំសម្របសម្រួលការ ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅ មិនទាន់គ្រប់គ្រាន់នៅឡើយ។
- យន្តការធ្វើសមាហរណកម្មការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ទៅ ក្នុងវិស័យសុខាភិបាល នៅក្នុងការសិក្សានៅឡើយ។
- តម្រូវការនូវការគាំពារសង្គមដល់ក្រុមអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជន គន្លឹះកាន់តែច្រើន។
- ការជានាលំហថវិកាជាតិដើម្បីបំពេញតម្រូវការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍ ក្នុងខណៈដែលការគាំទ្រថវិកាពីខាងក្រៅ មានការថយចុះជាលំដាប់។
- ការរៀបចំគោលការណ៍ប្រតិបត្តិ សម្រាប់កិច្ចសន្យាសង្គមឆ្លើយតបនឹងមេរោគ អេដស៍ និងជំងឺអេដស៍ នៅកំពុងដំណើរការ។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** ក៏បានបង្ហាញនូវទិសដៅបន្តដែលមានខ្លឹមសារដូចខាងក្រោម៖

- ជំរុញការធ្វើអន្តរាគមន៍បង្ការ ជាពិសេសលើក្រុមប្រជាជនគន្លឹះ និងស្វែងរកករណី អ្នកផ្ទុកមេរោគអេដស៍ថ្មី (ការផ្សព្វផ្សាយអប់រំ ការប្រើប្រាស់ស្រោមអនាម័យ PrEP, PEP, U=U, HIVST, PNTT)។

- ជំរុញការផ្តល់សោបង្ការថែទាំ កាត់បន្ថយការចម្លងមេរោគអេដស៍ ពីមាតាទៅទារក។
- បន្តជំរុញអនុវត្តលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ អំពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់រាជរដ្ឋាភិបាល ដោយបន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្ត ស.ជ.ណ២១៣ នៅរាជធានីភ្នំពេញ និងបណ្តាខេត្តគោលដៅ។
- បន្តអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (Fast-Track Cities: Ending the AIDS Epidemic) នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប (៨០លានរៀល) និងខេត្ត១១ផ្សេងទៀតដែលទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ៦០លានរៀល។
- បន្តកៀរគរហិរញ្ញប្បទានក្នុងស្រុក និងក្រៅស្រុក និងកំណត់អាទិភាពសកម្មភាពសម្រាប់ពង្រឹងប្រព័ន្ធជាតិ (Country System) ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ពិសេសសម្រាប់ការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ។
- ជំរុញការទទួលយកភាពជាម្ចាស់ក្នុងការដឹកនាំសម្របសម្រួលការឆ្លើយតបមេរោគអេដស៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ជំរុញការផ្តល់ចំណេះដឹង ស្តីពីការបង្ការមេរោគអេដស៍ និងជំរុញការចូលរួមពីក្រុមយុវវ័យក្នុងការងារបង្ការ ការធ្វើតេស្តឈាមរកមេរោគអេដស៍ ឱ្យបានទូលំទូលាយ។
- រៀបចំការប៉ាន់ប្រមាណការចំណាយក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ (NASA VII)។
- រៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ សម្រាប់ឆ្នាំ២០២៤-២០២៨។
- បន្តសម្របសម្រួលការរៀបចំការគាក់តែងគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

២. បទបង្ហាញ ស្តីពីគោលនគោបាយជាតិបញ្ចប់ជំងឺអេដស៍ឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ បង្ហាញជូនដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបង្ហាញពីគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍ឆ្នាំ២០២៥ ដែលមានចំនួន៧ គឺ៖

គោលនយោបាយទី១៖ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាលក្ខណៈពហុវិស័យ

- ក្នុងការអនុវត្តគោលនយោបាយជាតិ រាជរដ្ឋាភិបាលប្តេជ្ញាពង្រឹងភាពជាម្ចាស់ ការដឹកនាំសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពខ្ពស់ ការចូលរួមយ៉ាងសកម្មពីសំណាក់ដៃគូពាក់ព័ន្ធទាំងអស់ រួមទាំងដៃគូអភិវឌ្ឍន៍ ស្ថាប័នអន្តរជាតិ អង្គការសង្គមស៊ីវិល ជាតិ និងអន្តរជាតិ និងប្តេជ្ញាធ្វើការវិនិយោគឱ្យកាន់តែទូលំទូលាយក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- រាជរដ្ឋាភិបាលប្រគល់ការកិច្ចជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យធ្វើជាសេនាធិការប្រតិបត្តិផ្ទាល់ ក្នុងការដឹកនាំ អនុវត្តការងារបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមមាត្រា៤៣នៃច្បាប់ ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបំពេញការកិច្ចរៀងៗខ្លួនដូចខាងក្រោម ៖
  - អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានភារកិច្ចរៀបចំ ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ រៀងរាល់៥ឆ្នាំម្តង ដឹកនាំ សម្របសម្រួល និងចលនា ធនធាន ដើម្បីអនុវត្តផែនការ យុទ្ធសាស្ត្រជាតិ និងធ្វើការត្រួតពិនិត្យ លើប្រសិទ្ធភាពនៃយុទ្ធសាស្ត្រជាតិនេះ។
  - ក្រសួងសុខាភិបាល ត្រូវចូលរួមពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈកម្មវិធីថែទាំ ព្យាបាល និងកម្មវិធីបង្ការក្នុងវិស័យជីវៈវេជ្ជសាស្ត្រ (Biomedical)។ ក្រសួងសុខាភិបាល ត្រូវរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការបង្ការ ថែទាំ និងព្យាបាល ក្នុងវិស័យសុខាភិបាល។
  - ក្រសួង ស្ថាប័ន ថ្នាក់ជាតិត្រូវចូលរួមពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការសម្របសម្រួល និងវិស័យរៀងៗខ្លួន ទៅតាមគោលការណ៍ដូចមានចែងក្នុងគោលនយោបាយនេះ ឧទាហរណ៍៖ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និង

សហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងទេសចរណ៍ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រុមប្រឹក្សាជាតិគាំពារសង្គម ជាដើម។

- តាមការណែនាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍តាមវិស័យរៀងៗខ្លួន។
- រដ្ឋបាលថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ត្រូវចូលរួមពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយរៀបចំដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងអេដស៍គ្រប់លំដាប់ថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- តាមការណែនាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រដ្ឋបាលថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ត្រូវរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ដែនសមត្ថកិច្ចភូមិសាស្ត្រទទួលខុសត្រូវរៀងៗខ្លួន។
- ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន ត្រូវចូលរួមពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈយន្តការផ្តល់យោបល់ ដូចជា កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កិច្ចប្រជុំរួមរាជរដ្ឋាភិបាល-ដៃគូអភិវឌ្ឍន៍ កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស និងផ្តល់របាយការណ៍ទៀងទាត់អំពីសកម្មភាព និងអំពីស្ថានភាពហិរញ្ញវត្ថុនៃកម្មវិធីអេដស៍របស់ខ្លួន។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កលក្ខណៈឱ្យ អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះរៀបចំបណ្តាញសហគមន៍ ឬធ្វើឱ្យដំណើរការនៅសហគមន៍របស់ខ្លួន ដើម្បីចូលរួមក្នុងការប្រយុទ្ធនឹងជំងឺអេដស៍។ បណ្តាញសហគមន៍អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ត្រូវលើកទឹកចិត្តឱ្យចូលរួមក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធឆ្លើយតបជាតិពហុវិស័យក្នុងយន្តការជាតិតែមួយ តាមរយៈកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កិច្ចប្រជុំដៃគូអភិវឌ្ឍន៍។ល។

គោលនយោបាយទី២ ៖ ពង្រឹង ពង្រីក និងពន្លឿនកម្មវិធីបង្ការ

រាជរដ្ឋាភិបាលប្តេជ្ញា ពង្រឹង ពង្រីក និងពង្រឿន ការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអែដស៍ ដោយដាក់ចេញនូវវិធានការបង្ការជាក់លាក់ ទាំងខាងជីវវេជ្ជសាស្ត្រ ទាំងការផ្លាស់ប្តូរការប្រព្រឹត្ត និងដកចេញនូវឧបសគ្គ ឬរបាំងតាមផ្លូវច្បាប់ ឬបទបញ្ជាទាំងឡាយ ដើម្បីធានាថាប្រជាពលរដ្ឋប្រឈមមុខ បានទទួលសេវាបង្ការគ្របដណ្តប់ខ្ពស់ និងធានាឱ្យសេវាបង្ការទាំងនោះមានចីរភាពហើយ វិធានការទាំងនោះមានដូចតទៅ៖

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវដឹកនាំរៀបចំផែនទីចង្អុលផ្លូវនៃយុទ្ធសាស្ត្រ និងកម្មវិធីបង្ការការរីករាលដាលមេរោគអេដស៍ជាក់លាក់ យ៉ាងយូរនៅមុនដំណាច់ឆ្នាំ២០២៣ ដោយជ្រើសយកយុទ្ធសាស្ត្រ និងកម្មវិធីដែលមានគោលដៅច្បាស់លាស់ តាមរយៈការវាយតម្លៃ ដែលផ្តោតលើទំហំនៃសេចក្តីត្រូវការ និងលើរបាំងរារាំង ឬឧបសគ្គក្នុងការអនុវត្ត ដែលអាចសម្រេចបានចាប់ពីត្រីមាសទី១ ដល់ដំណាច់ឆ្នាំ២០២៤។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់កញ្ចប់ថវិកាទៅតាមទំហំនៃតម្រូវការ និងធានាថាកញ្ចប់ថវិកានោះអាចជួយគាំទ្រកម្មវិធីបង្ការការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយនិរន្តរភាព។ កញ្ចប់ថវិកានេះ អាចមានប្រភពចេញ ពីថវិកាជាតិ ថវិកាជំនួយ ឬចេញមកពីប្រភពផ្សេងទៀត។
- ក្នុងការប្រើប្រាស់ថវិកាសម្រាប់អនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីបង្ការនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវលើកសំណើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការវិភាជថវិកាដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។
- ដោយរាជរដ្ឋាភិបាលបានទទួលស្គាល់តួនាទីសំខាន់របស់អង្គការសង្គមស៊ីវិល ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវលើកសំណើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់ហិរញ្ញប្បទាន ឬជួលសេវាបង្ការ តាមរយៈកិច្ចសន្យាសង្គម ផ្តល់ទៅសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពការងារ និងជួយពង្រឹងសមត្ថភាព ព្រមទាំងជួយបង្កលក្ខណៈងាយស្រួល ដល់ការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានទទួលហិរញ្ញប្បទាន ឬជាប់កិច្ចសន្យាសង្គម ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវធ្វើការសិក្សា ឬវាយតម្លៃអំពីបទប្បញ្ញត្តិ ឬច្បាប់ទាំងឡាយណា ដែលអាចជារបាំង ឬឧបសគ្គក្នុងការអនុវត្តកម្មវិធីបង្ការការរាលដាលមេរោគអេដស៍ និងលើកសំណើទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកែលម្អបទប្បញ្ញត្តិ ឬច្បាប់ទាំងឡាយនោះ ក្នុងន័យឱ្យយុទ្ធសាស្ត្រ និងកម្មវិធីនោះប្រព្រឹត្តទៅដោយរលូន។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវធ្វើរបាយការណ៍ជូនគណៈរដ្ឋមន្ត្រីអំពីលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងលើកសំណើនូវវិធានការកែសម្រួល ជាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័ត្តមួយដងជារៀងរាល់ឆ្នាំ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវធានាថា ប្រជាជនកម្ពុជាទាំងអស់មានលទ្ធភាពទទួលបាននូវបច្ចុប្បន្នភាព ចំណេះដឹង ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ ដើម្បីប្រើប្រាស់ក្នុងការបង្ការ ថែទាំ ព្យាបាល និងគាំទ្រប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមផ្នែកទាំងបីនៃវិធានការបង្ការគឺ ការបង្ការបែបជីវវេជ្ជសាស្ត្រ ការបង្ការតាមការផ្លាស់ប្តូរការប្រព្រឹត្ត និងការបង្ការតាមបទប្បញ្ញត្តិ និងវិធានការច្បាប់នានា។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវធានារៀបចំឱ្យមានការអប់រំ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងសហការជាមួយក្រសួងសុខាភិបាល ដើម្បីបញ្ចូលជាផ្នែកមួយនៃការផ្តល់សេវាសុខាភិបាល តាមរយៈគ្រូពេទ្យ និងមន្ត្រីសុខាភិបាល។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រសួងសុខាភិបាល ត្រូវធានាថា ចំណេះដឹង និងសមត្ថភាពមន្ត្រីសុខាភិបាលត្រូវបានបំពាក់បំប៉នបន្ថែម រួមមានជំនាញសម្រាប់ផ្សព្វផ្សាយព័ត៌មាន និងការអប់រំ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ និងមានការបំពាក់បំប៉នបន្ថែមចំណេះដឹងនេះដល់មន្ត្រីសុខាភិបាល ទាំងផ្នែករដ្ឋ ទាំងផ្នែកឯកជន ត្រូវរួមបញ្ចូលក្រមសីលធម៌ជាពិសេសការរក្សាភាពសម្ងាត់ និងការគោរពសិទ្ធិបុគ្គលឬសិទ្ធិមនុស្ស។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវផ្តល់អនុសាសន៍ដល់ស្ថាប័នសាធារណៈ និងឯកជនឱ្យចូលរួមធ្វើការផ្សព្វផ្សាយព័ត៌មាន និងការអប់រំ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានរួមទាំងវិធានការបង្ការការឆ្លងរីករាលដាលឱ្យបានជាប្រចាំដូនមន្ត្រីបុគ្គលិក និយោជិតរបស់ខ្លួន។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល ជាពិសេស ជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាម (ម.ជ.ផ.ឈ.) ក្នុងការត្រួតពិនិត្យ ដើម្បីធានាថា អំណោយឈាម ដែលត្រូវផ្តល់ជូនអ្នកជំងឺ ត្រូវបានពិនិត្យថា គ្មានមេរោគអេដស៍ស្របតាមបទដ្ឋាន និងគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវផ្តល់អនុសាសន៍ដល់ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាថា ប្រជាជនទូទៅ ជាពិសេសក្រុមប្រឈមខ្ពស់ទទួលកញ្ចប់សេវាបង្ការរួមមាន ៖ ការចុះអប់រំផ្ទាល់ ឬប្រយោល ការធ្វើតេស្តឈាមរកមេរោគអេដស៍ ស្រោមអនាម័យ និងទឹករំអិល ឱសថបង្ការមុន(PrEP ប្រឹប) និងក្រោយការប្រឈមនឹងការចម្លងមេរោគអេដស៍(PEP ប៊ីប) ព្រមទាំងម្ជុល សឺរាុង។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវណែនាំក្រសួង ស្ថាប័ន រាជធានី ខេត្ត តាមរយៈគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ឱ្យអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ ១០០% ដើម្បីបង្ការការចម្លងមេរោគអេដស៍។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា ស្រោមអនាម័យអាចរក្សាទុក និងប្រើប្រាស់បាននៅគ្រប់គ្រឹះស្ថានបម្រើសេវាកម្មាន្ត ជាពិសេសនៅតាមសណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ បៀហ្គាឌិន កន្លែងម៉ាស្សា កោសជប់ ជាដើម។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាថា ស្រោមអនាម័យមិនត្រូវបានយកទៅធ្វើជាកស្តុតាងក្នុងការដាក់បន្ទុក ឬចោទប្រកាន់អំពីបទជួញដូរមនុស្ស ឬជួញដូរផ្លូវភេទឡើយ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវធានាថា ការរៀបចំយុទ្ធសាស្ត្រប្រើប្រាស់ស្រោមអនាម័យ ត្រូវតែមានវិធានការទាក់ទងនឹងការដឹកនាំ ការសម្របសម្រួល ការឃោសនាពាណិជ្ជកម្ម ការផ្គត់ផ្គង់ចែកចាយប្រកបដោយសុវត្ថិភាពទៅតាមតម្រូវការជាមួយនឹងខិតខំឱ្យមានការផ្លាស់ប្តូរឥរិយាបថនៃអ្នកប្រើប្រាស់ និងអ្នកចែកចាយ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល និងអង្គភាពជំនាញពាក់ព័ន្ធ ដើម្បីធានាថាអ្នកផ្តល់សេវាសុខាភិបាលទាំងរដ្ឋទាំងឯកជនអនុវត្តបានខ្ជាប់ខ្ជួននូវវិធានការក្នុងការបង្ការ និងគ្រប់គ្រងការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ចម្លងមេរោគអេដស៍តាមរយៈឧបករណ៍ សម្ភារៈប្រើប្រាស់ និងសំណល់វេជ្ជសាស្ត្រ ដូចមានចែងក្នុងមាត្រា៣នៃអនុក្រឹត្យ លេខ ២៨០ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល និងអង្គភាពជំនាញពាក់ព័ន្ធ ដើម្បីធានាថា អ្នកទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ទាំងអ្នកផ្ទុក ទាំងអ្នកជំងឺអេដស៍) បានអនុវត្តតាមវេជ្ជបញ្ជាយ៉ាងខ្ជាប់ខ្ជួនរហូតទទួលបានប្រសិទ្ធភាពខ្ពស់ ដែលនាំឱ្យបន្ទុកមេរោគអេដស៍ទាបបំផុត (Viral load suppression)។ ប្រសិទ្ធភាពនៃការព្យាបាលនេះ ត្រូវធ្វើឱ្យទៅជាផ្នែកមួយនៃវិធានការបង្ការការចម្លងមេរោគអេដស៍។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីធានាថា អ្នកដែលមានការប្រព្រឹត្តប្រឈមខ្ពស់នឹងការចម្លងមេរោគអេដស៍ ជាពិសេស ក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទ មានលទ្ធភាពទទួលបានឱសថប្រឆាំងមេរោគអេដស៍ ប្រើ

ប្រាស់សម្រាប់បង្ការមុនការប្រឈមនឹងការចម្លងមេរោគអេដស៍ (PrEP ប្រឹប) ស្រប តាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីធានាថា អ្នកដែលទទួលរងនូវការប្រឈមនឹងការចម្លងមេរោគអេដស៍ដោយសារមុខរបរ (វិជ្ជាជីវៈពេទ្យ) ឬដោយសារការរំលោភផ្លូវភេទ ឱ្យមានលទ្ធភាពទទួលបាននូវឱសថប្រឆាំងមេរោគអេដស៍ប្រើប្រាស់សម្រាប់បង្ការការចម្លងមេរោគអេដស៍ ក្រោយពីបានប្រឈមនឹងការចម្លងមេរោគអេដស៍ (PEP ប៊ីប)។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ដើម្បីធានាថា ប្រជាជនកម្ពុជាដែលសង្ស័យថាមានផ្ទុកមេរោគអេដស៍ ទទួលបាននូវសេវាប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងដោយរក្សាការសម្ងាត់ ហើយគោលនយោបាយគាំពារសង្គមដែលកំពុងអនុវត្ត អាចប្រើប្រាស់ជាការជួយលើកទឹកចិត្តក្រុមប្រឈមខ្ពស់ ឱ្យមកធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាពិសេស ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីសិក្សាអំពីលទ្ធភាពផ្តល់កញ្ចប់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រុមប្រឈមមុខខ្ពស់ឱ្យមកធ្វើតេស្តឈាមរកមេរោគអេដស៍ឱ្យបានទូលំទូលាយ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល ជាពិសេសមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា ស្ត្រីមានផ្ទៃពោះទាំងអស់ ត្រូវទទួលបានសេវាបង្ការការចម្លងមេរោគអេដស៍ ពីមាតាទៅទារក ឆ្ពោះទៅបញ្ចប់ការចម្លងមេរោគអេដស៍ពីមាតាទៅទារកឱ្យបានឆាប់ជាទីបំផុត។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល ដើម្បីធានាថា ទារកអាយុ២ខែដែលម្តាយមានផ្ទុកមេរោគអេដស៍ និងបន្ទាប់ពីផ្តាច់ដោះទទួលបានការធ្វើតេស្តរកមេរោគអេដស៍។ ដោយឡែក ទារកដែលរកឃើញថាបានឆ្លងមេរោគអេដស៍ត្រូវទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ប្រកបដោយប្រសិទ្ធភាពខ្ពស់។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវផ្តល់ការណែនាំដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ដែលកំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យខិតខំប្រឹងប្រែងទ្វេដង ក្នុងការអនុវត្តគោលនយោបាយពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការការឆ្លងរកមេរោគអេដស៍នេះ។

គោលនយោបាយទី៣៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីថែទាំ និងព្យាបាល

រាជរដ្ឋាភិបាលប្តេជ្ញាពង្រីក ពង្រឹង និងពន្លឿនកម្មវិធីថែទាំ និងព្យាបាល ដោយរកឱ្យឃើញអ្នកលាក់មុខមិនមកទទួលសេវាព្យាបាលថែទាំ បង្កលក្ខណៈឱ្យអ្នកសង្ស័យថាផ្ទុកមេរោគអេដស៍ មកធ្វើតេស្តឈាមរកមេរោគអេដស៍ និងទាមទារឱ្យអ្នកជំងឺដែលទទួលការព្យាបាលថែទាំ កុំបោះបង់សេវាព្យាបាលថែទាំ។ ដើម្បីសម្រេចគោលដៅខាងលើនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចតទៅ ៖

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកប្រឈមមុខខ្ពស់ ជាពិសេសយុវវ័យ ឱ្យចូលរួមក្នុងកិច្ចអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍យ៉ាងសកម្ម និងទូលំទូលាយ កែសម្រួលសេវាព្យាបាលថែទាំឱ្យមានលក្ខណៈសេវាមេត្រី (Friendly service) កាត់បន្ថយការរើសអើងនៅក្នុងសហគមន៍ គ្រួសារ កន្លែងធ្វើការ និងមន្ទីរពេទ្យ។

គោលនយោបាយទី៤៖ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម

រាជរដ្ឋាភិបាលប្តេជ្ញាពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម ដើម្បីផ្តល់សេវាគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ដែលត្រូវបានចាត់ទុកជាជនក្រីក្រក្នុងសហគមន៍ ដោយមិនទុកនរណាម្នាក់ចោលនោះឡើយ ហើយដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចតទៅ ៖

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេស ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីធានាថា ៖
    - អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ទទួលបានអត្តសញ្ញាណកម្មគ្រួសារក្រីក្រជាលក្ខណៈបុគ្គល។
    - ប្រជាជនប្រឈមខ្ពស់នឹងការចម្លងមេរោគអេដស៍ដូចជា អ្នកបម្រើសេវាកម្សាន្តសប្បាយ បុរសរួមភេទជាមួយបុរស ក្រុមបំផ្លែងភេទ មានលទ្ធភាពទទួលបានប.ស.ស ឬប័ណ្ណសមធម៌សុខាភិបាល។
    - រៀបចំយន្តការក្នុងការផ្តល់ប័ណ្ណសមធម៌សុខាភិបាល ដល់អ្នកបម្រើសេវាកម្សាន្តសប្បាយ នៅកន្លែង ម៉ាស្សា ស្ទឹម សោណា កោសជប់ តាមសួនសាធារណៈ ជាដើម។ ដោយឡែក ចំពោះអ្នកលាក់មុខ ឬគ្មានអត្តសញ្ញាណច្បាស់លាស់ ក្រសួង ស្ថាប័នមានសមត្ថកិច្ចអាចយកកស្តង់នៃការធ្វើតេស្តរកមេរោគអេដស៍ជាមូលដ្ឋានក្នុងការផ្តល់ប័ណ្ណសមធម៌សុខាភិបាល ឬអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។
    - អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំយុទ្ធនាការអប់រំ និងធ្វើតេស្តឈាមរកមេរោគអេដស៍ ស្របពេលដែលក្រុមប្រឈមខ្ពស់មកចុះឈ្មោះធ្វើអត្តសញ្ញាណកម្ម

ដើម្បីទទួលអត្ថប្រយោជន៍ពីកម្មវិធីគាំពារសង្គមដូចជា ប័ណ្ណសមធម៌សុខាភិបាល ឬ អត្តសញ្ញាណកម្មគ្រួសារ ឬបុគ្គលក្រីក្រជាដើម។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងសុខាភិបាល ដើម្បីធានាថា ស្ត្រីមានផ្ទៃពោះបានទទួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយ ទៅកូន ចាប់ពីពេលមានផ្ទៃពោះរហូតដល់ កូនមានអាយុ២ឆ្នាំ។

គោលនយោបាយទី៥៖ បញ្ចប់ការរើសអើង និងមាក់ងាយ

រាជរដ្ឋាភិបាលប្តេជ្ញាបញ្ចប់ការរើសអើង និងមាក់ងាយអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដោយហេតុ ថាការរើសអើង និងមាក់ងាយនាំឱ្យមានវិសមភាពនៅក្នុងសង្គម ឬសហគមន៍ និងជាឧបសគ្គរារាំងដល់ការផ្តល់ សេវាបង្ការ ព្យាបាល និងថែទាំដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ចំណែកការរើសអើង និងមាក់ងាយនេះក៏ ជាកត្តាអាចធ្វើឱ្យមានការចម្លងមេរោគអេដស៍ថ្មី និងការស្លាប់មានការកើនឡើង ក្នុងនោះដែរដើម្បីបញ្ចប់នូវការរើសអើង និងមាក់ងាយ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចតទៅ៖

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវណែនាំក្រសួង ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ឱ្យសហការគ្នាដើម្បី ៖
  - ឱ្យការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស សមភាព រក្សាឯកជនភាពនិងរក្សាការសម្ងាត់។
  - ធានាថាគ្មានប្រជាជនកម្ពុជាណាម្នាក់ត្រូវបានទុកចោល ឬដាក់ឱ្យនៅឯកកោដោយសារតែមេរោគអេដស៍ និងជំងឺអេដស៍ទេ។
  - ធានាលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងមាក់ងាយទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ និងក្រុមគោលដៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រោះការរើសអើង និងមាក់ងាយជាបទល្មើសទៅនឹងច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវណែនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលអនុវត្តកម្មវិធីអេដស៍ ឱ្យរៀបចំយុទ្ធសាស្ត្រ និងកម្មវិធីលម្អិតបញ្ចប់ការរើសអើង និងមាក់ងាយចំពោះអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ ដោយធានាឱ្យមានការយល់ដឹង និងការប្រព្រឹត្តជាវិជ្ជមាន ដើម្បីបញ្ចប់ការរើសអើង និងមាក់ងាយ ចាប់ផ្តើមពីបុគ្គល ទៅគ្រួសារ និងរហូតដល់សហគមន៍ទាំងមូល។

គោលនយោបាយទី៦៖ ចលនាធនធាន

រាជរដ្ឋាភិបាលប្តេជ្ញាចលនាប្រភពធនធានសមស្រប ដើម្បីអនុវត្តគោលនយោបាយជាតិឱ្យបានជោគជ័យ ចលនាធនធាននោះមានរួមទាំង ការវិភាជថវិកា ការសុំហិរញ្ញប្បទានក្រៅ

ប្រទេស ឬកម្ចីពីស្ថាប័នអន្តរជាតិជាដើម ដើម្បីគាំទ្រគោលនយោបាយជាតិនេះ រាជរដ្ឋាភិបាលជាក់ចេញនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវពិគ្រោះយោបល់ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បង្កើនថវិកា ដើម្បីធ្វើការ វិនិយោគតាមតម្រូវការ ក្នុងការបញ្ចប់អេដស៍ និងជានាចីរភាពកម្មវិធីឆ្លើយតបនឹងជំងឺអេដស៍ តាមរយៈការរិភាជថវិកាជាតិ ឬការកៀរគរថវិកាពីប្រភពខាងក្រៅ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការសិក្សាយុទ្ធសាស្ត្រចាកចេញ (Exit Strategy) ដើម្បីរកថវិកាបម្រុងទុកក្នុងការជានាចីរភាពកម្មវិធីអេដស៍ មុនពេលជំនួយពីក្រៅប្រទេសត្រូវបានបញ្ចប់ នៅក្នុងរង្វង់ឆ្នាំ២០២៩-២០៣០។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវស្វែងរកថវិកា តាមរយៈថវិកាជាតិ ជំនួយឥតសំណងកម្ចីពីស្ថាប័ន អន្តរជាតិ ដើម្បីជានាថា គោលនយោបាយបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍នេះអាចអនុវត្តបានប្រកបដោយជោគជ័យ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាចរិភាជថវិកាជាតិផ្តល់ជូនក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ដែលមានគោលដៅច្បាស់លាស់។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាចផ្តល់ហិរញ្ញប្បទាន ឬជួលសេវាតាមរយៈកិច្ចសន្យាសង្គម ដល់អង្គការសង្គមស៊ីវិលដែលមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងសុខាភិបាល ត្រូវសហការគ្នាដើម្បីជានាថា កម្ពុជានៅតែមានលទ្ធភាពផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់អ្នកផ្ទុកមេរោគអេដស៍ដោយឥតគិតថ្លៃ នៅពេលដែលកម្ពុជាចាកផុតពីចំណាត់ថ្នាក់ជាប្រទេសមានចំណូលមធ្យមកម្រិតទាប។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវទទួលខុសត្រូវក្នុងការប៉ាន់ប្រមាណអំពីទំហំនៃសេចក្តីត្រូវការ និងត្រូវតម្រង់ទិសការប្រើប្រាស់ធនធានជាតិ និងអន្តរជាតិឱ្យប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍អាចជូនដំណឹងទៅប្រមុខរាជរដ្ឋាភិបាលអំពីលទ្ធភាពស្វែងរកធនធានជាតិ និងអន្តរជាតិ និងលើកសំណើឱ្យមានការគ្រប់គ្រងធនធានទាំងនោះតាមច្រកចេញចូលតែមួយក្នុងការប្រើប្រាស់ឱ្យបានត្រឹមត្រូវទៅតាមអាទិភាព និងមានប្រសិទ្ធភាពខ្ពស់។

គោលនយោបាយទី៧៖ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធតាមដាន និងវាយតម្លៃជាតិ

រាជរដ្ឋាភិបាល ប្តេជ្ញាអនុវត្តគោលការណ៍បី-មួយ នោះគឺស្ថាប័នសម្របសម្រួលតែមួយផែនការយុទ្ធសាស្ត្រជាតិតែមួយ និងប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយ ដើម្បីឱ្យការ

អនុវត្តគោលនយោបាយនេះបានជោគជ័យ។ ការពង្រឹងប្រសិទ្ធភាពប្រព័ន្ធតាមដាន និងវាយតម្លៃជាតិតែមួយ ជាការរួមចំណែកមិនអាចខ្វះបានក្នុងការអនុវត្តគោលនយោបាយជាតិនេះឱ្យមានប្រសិទ្ធភាព។ ការពង្រឹងប្រព័ន្ធតាមដានវាយតម្លៃនេះធ្វើឡើង ដើម្បីជានាថាការសម្រេចចិត្តផ្នែកគោលនយោបាយ ការរៀបចំយុទ្ធសាស្ត្រ និងផែនការ ព្រមទាំងការវិភាជធនធាននៅថ្នាក់ជាតិ និងក្រោមជាតិបានទិន្នន័យច្បាស់លាស់គួរទុកចិត្តបានជាសំអាង និងនាំមកនូវការផ្លាស់ប្តូរដោក់លាក់។ ដូច្នេះរាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដូចតទៅ៖

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវណែនាំក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការសង្គមស៊ីវិល ឱ្យប្រមូល រៀបចំ វិភាគ និងប្រើប្រាស់ជាប្រយោជន៍ក្នុងការឆ្លើយតបឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពជាក់ស្តែងរបស់ខ្លួននូវទិន្នន័យ ស្តីពីស្ថានភាពរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ វឌ្ឍនភាព និងប្រសិទ្ធភាពនៃការឆ្លើយតប។
- ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការសង្គមស៊ីវិលត្រូវផ្តល់ទិន្នន័យខាងលើដែលប្រកបដោយភាពច្បាស់លាស់គួរទុកចិត្តបានមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឱ្យបានទៀងទាត់ជាប់ជាប្រចាំ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវណែនាំក្រសួងសុខាភិបាលឱ្យបន្តការធ្វើអង្កេតការប្រព្រឹត្ត និងការរាលដាលមេរោគអេដស៍ (IBBS) ឱ្យបានទៀងទាត់។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលក្នុងរៀបចំការវិនិយោគទៅលើការសិក្សាស្រាវជ្រាវក្នុងករណីចាំបាច់ដើម្បីលើកកម្ពស់ការឆ្លើយតបឱ្យកាន់តែប្រសើរឡើង។
- តាមរយៈប្រព័ន្ធតាមដាន វាយតម្លៃ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវធ្វើរបាយការណ៍ពីស្ថានភាពរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ និងវឌ្ឍនភាពប្រសិទ្ធភាព និងសមិទ្ធផលនៃការឆ្លើយតបជារៀងរាល់ឆ្នាំ ជូនប្រមុខរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការផ្សព្វផ្សាយរបាយការណ៍ខាងលើឱ្យ បានទូលំទូលាយជូនសាធារណជន។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការពិនិត្យឡើងវិញនូវការអនុវត្តផែនការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានទៀងទាត់ជារៀងរាល់ឆ្នាំ ដើម្បីស្វែងយល់ពីគម្លាតនៃការឆ្លើយតប និងដើម្បីលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យ និងកែលម្អសម្រាប់ការអនុវត្តនៅឆ្នាំបន្តបន្ទាប់ទៀត។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវធ្វើការវាយតម្លៃក្នុងកម្រិតជាតិមួយ ដោយមានការចូលរួមពីអ្នកជំនាញឯករាជ្យនៅឆ្នាំ២០២៦ ដើម្បីកំណត់ពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីដាក់ចេញវិធានការកែលម្អ លើចំណុចខ្វះខាតក្នុងការអនុវត្តគោលនយោបាយលុបបំបាត់ជំងឺអេដស៍។

៥. មតិយោបល់សមាជិកកិច្ចប្រជុំពេញអង្គ

ឯកឧត្តមរដ្ឋមន្ត្រី អៀង មុលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានប្រសាសន៍៖

- សូមក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ នៅពេលប្រគល់ប័ណ្ណ ប.ស.ស សូមបញ្ចុះបញ្ចូលធ្វើយ៉ាងណាឱ្យពួកគាត់ធ្វើតេស្តរកមេរោគអេដស៍ជាមុនសិន។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ណែនាំ សហការ ផ្សព្វផ្សាយឱ្យធ្វើតេស្ត ឬប្រើស្រោមអនាម័យ ចំពោះនារីបម្រើសេវាកម្មាន្ត និងបុរសរួមភេទជាមួយបុរស ១ឆ្នាំ ១២លានស្រោម គឺមិនគ្រប់ទេ។
- លើកទឹកចិត្តម្តាយឱ្យធ្វើតេស្តឈាមរកមេរោគអេដស៍
- ត្រូវពង្រឹងប្រព័ន្ធជាតិ ការបង្ការត្រូវមានផែនទីបង្ហាញផ្លូវត្រូវធ្វើអ្វីខ្លះ
- បញ្ជាក់ជូនសមាជិក សមាជិកានៃកិច្ចប្រជុំថា សេចក្តីព្រាងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នេះនឹងឆ្លងកិច្ចពិគ្រោះយោបល់ ជាមួយសមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួងតាក់តែងគោលនយោបាយបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។
- ស្នើសុំឱ្យមានការកែសម្រួលគោលបំណងចែងថា សូន្យនៃការឆ្លងថ្មី សូន្យនៃការស្លាប់ទាក់ទងនឹងជំងឺអេដស៍ និងសូន្យនៃការរើសអើង ស្របតាមបច្ចុប្បន្នភាពនៃស្ថានភាពរីករាលដាលនៃមេរោគអេដស៍។

ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉ែត ដោយឈរលើហេតុផលបច្ចេកទេសនៃការគេណនាតាមបែបវិទ្យាសាស្ត្រ **ឯកឧត្តមរដ្ឋមន្ត្រី** បានបញ្ជាក់ពីការប្រែប្រួលលើតួលេខមួយចំនួន៖

- គោលដៅ៩៥%ទីមួយ សម្រេចបាន៨៤% មកជា៨៦% វិញ ចំណែកឯចំនួនអ្នកផ្ទុកមេរោគអេដស៍តាមការប៉ាន់ប្រមាណ ៧៤ ០០០នាក់ មកជា ៧៦ ០០០នាក់ វិញ និងអ្នកឆ្លងថ្មីមេរោគអេដស៍១ ២០០នាក់ មកជា ១ ៤០០នាក់ វិញ។
- ការបញ្ជាបសារអប់រំត្រូវចូលឱ្យដល់ក្រុមគោលដៅជាពិសេសក្រុមបុរសរួមភេទជាមួយបុរសដែលជាក្រុមដែលមានអត្រាឆ្លងមេរោគអេដស៍ខ្ពស់។

- ក្រសួង ស្ថាប័នពាក់ព័ន្ធជួយណែនាំឱ្យអ្នកសង្ស័យពីស្ថានភាពមេរោគអេដស៍របស់ខ្លួនមកធ្វើតេស្តឈាមរកមេរោគអេដស៍ និងប្រើស្រោមអនាម័យជាប់លាប់គ្រប់ពេលរួមភេទ។
- ជំរុញផ្សព្វផ្សាយលើកទឹកចិត្តឱ្យស្ត្រីបំរើសេវាកំសាន្តឯករាជ្យ(តាមសួនសាធារណៈ) ទៅធ្វើតេស្តឈាមរកមេរោគអេដស៍មុនផ្តល់ប័ណ្ណសមធម៌ និងសម្របសម្រួលក្រុមប្រឈមទទួលបានការគាំពារសង្គមដូចជាប័ណ្ណប.ស.ស។
- ជំរុញផ្សព្វផ្សាយលើកទឹកចិត្តឱ្យស្ត្រីមានផ្ទៃពោះទៅធ្វើតេស្តឈាមរកមេរោគអេដស៍ (អត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅទារកនៅកម្ពុជាខ្ពស់ជាងប្រទេសថៃ)។

លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា៖

- ក្រសួងអប់រំ យុវជននិងកីឡា មានតួនាទីសំខាន់ក្នុងការទប់ស្កាត់មេរោគអេដស៍សម្រាប់យុវវ័យ(អាយុពី១៥-២៤)ជាកម្លាំងពលកម្មសេដ្ឋកិច្ចសង្គម។
- ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧ បានធ្វើការកែទម្រង់ការងារអប់រំ ដោយដាក់កម្មវិធីតាមគ្រឹះស្ថានសិក្សាពីថ្នាក់ទី១ដល់ថ្នាក់ទី១២គឺ១ម៉ោង ក្នុងមួយសប្តាហ៍ និងថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ដាក់កម្មវិធីអប់រំសុខភាពផ្លូវភេទ និងបន្តពូជ ព្រោះភាគច្រើនយុវវ័យពីអាយុ១៥ដល់២៤ឆ្នាំមានអត្រាឆ្លងខ្ពស់។
- រៀបចំយុទ្ធសាស្ត្រ ដោយធ្វើយុទ្ធនាការផ្សព្វផ្សាយជំរុញលើកទឹកចិត្តឱ្យទៅធ្វើតេស្តឈាមរកមេរោគអេដស៍ភ្ជាប់ជាមួយការផ្តល់ប័ណ្ណសមធម៌សម្រាប់ក្រុមប្រឈមមុខ។
- ត្រូវរៀបចំប្រព័ន្ធតាមដាន និងប្រើប្រាស់ទិន្នន័យជាកញ្ចក់ឆ្លុះបញ្ចាំងការអនុវត្ត ពីព្រោះថា បើមានការសម្របសម្រួលមួយត្រឹមត្រូវនោះការចំណាយសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ មិនអស់ច្រើនទេ។
- ក្រសួងអប់រំយុវជន និងកីឡានឹងធ្វើបច្ចុប្បន្នភាពលើសម្ភារៈឧបទ្ទេស(*Educational Tools*)សម្រាប់កម្មវិធីអប់រំសុខភាពបន្តពូជ(ថ្នាក់ពី៧ដល់ថ្នាក់១២) ទាំងកម្មវិធីសិក្សា និងប្រព័ន្ធផ្សព្វផ្សាយសង្គម។

លោកជំទាវ កែវ ចរិយា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្នើលើកយកចំណុចទី៦នៃគោលនយោបាយលុបបំបាត់ជំងឺអេដស៍ ប្រជុំផ្ទៃក្នុងរវាងនាយកដ្ឋានពាក់ព័ន្ធ(នាយកដ្ឋានសហប្រតិបត្តិការពហុភាគ អគ្គនាយកដ្ឋានថវិកាថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាជាតិគាំពារសង្គម និងផ្នែកផ្សេងៗទៀត)។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្នើសុំសារអប់រំដែលផលិតដោយក្រុមបច្ចេកទេសដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។

ក្រសួងព័ត៌មាន៖

- ក្រសួងព័ត៌មានស្នើសុំថវិកាផលិតកម្មវិធីពិភាក្សាតុមូល និងកម្មវិធីអប់រំបង្ការមេរោគអេដស៍ចាក់ផ្សាយតាមអេប (Apps) ដែលក្រសួងមាន។

៦.អនុម័ត លើសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គ៖

បន្ទាប់ពីការពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយមក សមាជិក សមាជិកាទាំងអស់ បានប្តេជ្ញាបន្តរួមគ្នាក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលមេរោគអេដស៍ និងក្នុងឆន្ទៈរួមឆ្ពោះទៅបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបជំងឺអេដស៍ឆ្នាំ២០២៣-២០២៨ កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៣ បានដាក់ចេញនូវការសម្រេចចិត្តដូចតទៅ៖

១. ជំរុញយុទ្ធសាស្ត្រឆ្ពោះទៅសម្រេចគោលដៅ៩៥ ទី១ (៩៥% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ) តាមរយៈការជំរុញការងារបង្ការនៃការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព និងការជំរុញលើកទឹកចិត្តអ្នកមានការសង្ស័យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ឱ្យបានឆាប់រហ័ស។

២. ជំរុញក្រសួងទេសចរណ៍បន្តយន្តការជំរុញលើកទឹកចិត្តដល់ គ្រប់គ្រឹះស្ថានកម្សាន្ត សប្បាយ សណ្ឋាគារ និងកន្លែងកម្សាន្តនានានៅទូទាំងប្រទេស ឱ្យចូលរួមអនុវត្តគោលនយោបាយនៃការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ ឱ្យបានទូលំទូលាយ។

៣. ជំរុញក្រសួងអប់រំ យុវជន និងកីឡា បង្កើនការងារអប់រំផ្សព្វផ្សាយការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានទូលំទូលាយនៅតាមសាលារៀន គ្រឹះស្ថានឧត្តមសិក្សា ទាំងរដ្ឋ និងឯកជន ដើម្បីការពារ និងកាត់បន្ថយការឆ្លងមេរោគអេដស៍ក្នុងចំណោមយុវជន។

៤. ជំរុញក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើនការងារអប់រំផ្សព្វផ្សាយការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យបានទូលំទូលាយដល់កម្មករ កម្មការិនី និងនិយោជិត នៅតាមរោងចក្រ សហគ្រាស នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

៥. ជំរុញមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) នៃក្រសួងសុខាភិបាល បង្កើន និងពង្រីកតំបន់គ្របដណ្តប់នៃសេវាផ្តល់ឱសថការពារមេរោគអេដស៍ជាមុន (PrEP) នៅតាមបណ្តារាជធានី ខេត្ត។

៦. គាំទ្រការដាក់ចេញគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបជំងឺអេដស៍ ឆ្នាំ២០២៣-២០២៨។

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គបានធ្វើបទបង្ហាញរួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស ដែលនាំឱ្យកិច្ចប្រជុំនេះទទួលបាននូវលទ្ធផលគួរជាទីមោទនៈសមស្របទៅនឹងកម្មវត្ថុនៃកិច្ចប្រជុំនាពេលនេះ **ឯកឧត្តមឧទេសរដ្ឋមន្ត្រី** ក៏បានសង្ខេបជូនដូចតទៅ ៖

ទី១: ការអនុម័តជាគោលការណ៍នូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ រយៈពេល៦ខែដើម ឆ្នាំ២០២៣។

ទី២: ការបន្តជំរុញឱ្យមានវឌ្ឍនភាព និងការបន្តការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ទី៣: ការអនុម័តសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី ១ ឆ្នាំ២០២៣ សម្រាប់បន្តអនុវត្តក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឆ្ពោះទៅសម្រេចបាននូវគោលដៅ ៩៥-៩៥-៩៥ នាឆ្នាំ២០២៥។

ទោះបីជាពេលវេលានៃកិច្ចប្រជុំនេះមានពេលមួយព្រឹកក៏ពិតមែន តែដោយសារមានការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កា ដែលខ្ញុំសូមយកឱកាសនេះ សម្តែងនូវការកោតសរសើរដ៏ស្មោះបំផុត ជូនសមាជិក សមាជិកានៃអង្គពិធីទាំងមូល។រយៈពេលបីឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាល បានចូលរួមវិភាជថវិកាលើការឆ្លើយតបមេរោគអេដស៍ចំនួនប្រមាណ២៣% ធៀបនឹងចំនួនថវិកាសរុបសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។ តាមរយៈសូចនាករួមតាមដានរួមគ្នាឆ្នាំ២០១៩-២០២៣ ដែលរាជរដ្ឋាភិបាលប្តេជ្ញាអនុវត្តដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ដល់ឆ្នាំ២០២០ ថវិកាក្នុងស្រុកបានកើនដល់៣៥% នៃការចំណាយលើការងារអេដស៍។ នៅឆ្នាំ២០២៣ រាជរដ្ឋាភិបាលក៏បានវិភាជថវិកាចំនួន៦០លានរៀលក្នុងមួយឆ្នាំក្នុងមួយខេត្ត ដល់ខេត្តចំនួន១១ និងនៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលក៏បានគ្រោងវិភាជថវិកាចំនួន ៤០លានរៀលក្នុងមួយឆ្នាំក្នុងមួយខេត្ត ដល់ខេត្តចំនួន១០ ចុងក្រោយទៀត។ ជាសរុបចាប់ពីឆ្នាំ

២០២២ ដើម្បីជំរុញការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបាន និងគ្រោងវិភាជថវិកាចំនួន១.៣៨០លានរៀលក្នុងមួយឆ្នាំ ដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្តទាំង២៥ សម្រាប់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានផ្តល់ជូននូវចំណាប់អារម្មណ៍ បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះដូចខាងក្រោម ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែដើមឆ្នាំ២០២៣ ទៅតាមក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២) សូមអបអរសាទរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួម និងផ្តួចផ្តើមឱ្យមានកិច្ចប្រជុំនានា ដើម្បីឆ្លើយតបនឹង «សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស» ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលមកទល់ពេលនេះ បានសម្របសម្រួលដល់ការផ្តល់ និងប្រើប្រាស់កញ្ចប់ថវិកាជាតិ ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់បណ្តាខេត្តដែលមានហានិភ័យផ្សេងទៀត។

៣) សូមលើកទឹកចិត្តជូនគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ឱ្យបន្តជំរុញនិងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំសង្កាត់ ក្នុងការអនុវត្ត «សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស» ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

៤) បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបន្តសិក្សាលើលទ្ធភាពប្រើប្រាស់អត្ថប្រយោជន៍គាំពារ សង្គមក្នុងការគាំទ្រដល់ការងារឆ្លើយតបនឹងការរាលដាលមេរោគអេដស៍ ជាពិសេសក្នុងការលើកទឹកចិត្តឱ្យប្រជាជនគន្លឹះស្ម័គ្រចិត្តមកធ្វើតេស្តឈាមរកមេរោគអេដស៍។ កិច្ចអន្តរាគមន៍គាំពារសង្គមដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះ អាចចាត់ទុកជាមធ្យោបាយមួយ ក្នុងការបង្កើនការមកទទួលយកសេវាសុខភាព ក្នុងនោះរួមទាំងការធ្វើតេស្តឈាមរកមេរោគអេដស៍ សម្រាប់ក្រុមប្រជាជនគន្លឹះផង។

៥) កង្វះខាតថវិកានៅតែជាបញ្ហាចម្បងមួយ រារាំងដល់ការអនុវត្តផែនការសកម្មភាពឱ្យបានពេញលេញទៅតាមការគ្រោងទុក ឬក៏លទ្ធភាពក្នុងការពង្រីកអត្រាគ្របដណ្តប់ទៅកាន់ក្រុមគោលដៅថ្មី ជាពិសេសក្រុមប្រជាជនគន្លឹះ។

ជាកិច្ចបញ្ចប់ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងសន្ទរកថាបិទកិច្ចប្រជុំដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម៖

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញរួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុសផុលដែលនាំឱ្យទទួលបាននូវលទ្ធផលគួរជាទីមោទនៈ សមស្របទៅនឹងកម្មវត្ថុ នៃកិច្ចប្រជុំ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ថ្លែងសុន្ទរកថាបិទ និងផ្តល់អនុសាសន៍ដូចខាងក្រោមៈ

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពនាពេលខាងមុខ។

២) ជំរុញ និងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យក្នុងការអនុវត្ត "សេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៣) ប្រឹងប្រែងអនុវត្តសេចក្តីសម្រេចចិត្តនៃសម័យប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២ ដែលទើបបានទទួលការអនុម័តនាពេលនេះ។

៤) បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័ន ដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកាឆ្នាំ២០២៣ ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួង ស្ថាប័នសាមីឱ្យបានព្រមៗគ្នា។

៥) បន្តជំរុញការអនុវត្ត រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីសម្រេចឱ្យបានជោគជ័យនូវ កម្មវិធីគំនិតផ្តួចផ្តើមទីក្រុងរួមគ្នាពន្លឿនការឆ្លើយតបការរីករាលដាលជំងឺអេដស៍ (Fast-Track Cities Initiative) ដែលបាន និងកំពុងដំណើរការនៅក្នុងទីក្រុងភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងបន្ទាយមានជ័យ។

៦) លើកទឹកចិត្តជូនខេត្តចំនួន១១ បន្ថែមទៀត ឱ្យរៀបចំផែនការសកម្មភាព និងថវិកាឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៧) សូមលើកទឹកចិត្តជូនក្រសួងផែនការ ក្រសួងសុខាភិបាល និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បន្តធ្វើការសហការជំរុញផ្តល់ប័ណ្ណក្រីក្រ ជល់ អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ជាបុគ្គល នៅតាម ART sites ឱ្យបានកាន់តែច្រើនបន្ថែមទៀត។

៨) បន្តរុករកអ្នកដែលមិនទាន់បានមកទទួលសេវា ឱ្យមកទទួលយកសេវា បង្កើនការគ្របដណ្តប់ និងផ្តល់អន្តរាគមន៍ឱ្យមានប្រសិទ្ធិភាព ទៅលើក្រុមប្រឈម ពិសេសក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំផ្លែងភេទ ដោយបង្កើនតំបន់គ្របដណ្តប់កម្មវិធី PrEP ឱ្យបានទូលំទូលាយ និងកាន់តែមានប្រសិទ្ធភាព។

៩) បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់បន្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅ